

# ជំពូកទី ៩
# សុវត្ថិភាព

នៅពេលកុមារចាប់ផ្ដើមចេះវារ ឬ ដើរលើកដំបូង ជារឿយៗយើងច្រើនតែយកចិត្តទុកដាក់ចំពោះសុវត្ថិភាពរបស់ពួកគេ ។ នៅពេលកុមារកំពុងរៀនបំលាស់ទីតាំងជុំវិញខ្លួន គេក៏រៀនចៀសវាងអ្វីៗដែលអាចបង្កគ្រោះថ្នាក់ចំពោះគេដែរ ។ កុមារដែលមើលឃើញអាចចៀសវាងគ្រោះថ្នាក់បានច្រើន ។ តែអ្នកត្រូវប្រយ័ត្នថែមទៀត បើកូនមិនអាចមើលឃើញច្បាស់ ។

អ្នកអាចធ្វើឱ្យលំនៅដ្ឋានរបស់អ្នកកាន់តែមានសុវត្ថិភាពតាមករណីជាច្រើន និងបង្រៀនកូនអំពីគ្រោះថ្នាក់ ។ អ្នកអាចធ្វើឱ្យស្រុកភូមិផងរបងជាមួយកាន់តែមានសុវត្ថិភាពសំរាប់កូន និងអ្នកដទៃ ដោយធ្វើការរួមគ្នាជាមួយអ្នកស្រុកភូមិនៅក្នុងសហគមន៍របស់អ្នក-ជារឿយៗការផ្លាស់ប្ដូរល្អបែបនេះនឹងមានផលប្រយោជន៍ដល់មនុស្សជាច្រើន ។

## ➤ វិធីជួយកូនឱ្យចេះបំលាស់ទីតាំងនៅផ្ទះប្រកបដោយសុវត្ថិភាព

ចូរបិទបាំងជ្រុងគ្រឿងសង្ហារឹម ( តុ, ទូរ, កៅអី) ទូរចានឆ្នាំង និងវត្ថុដែលមានជ្រុងស្រួចៗ ។ ចូរចងចាំថា ជ្រុងស្រួចៗ ឬ កែងទាំងឡាយមិនត្រឹមតែមាននៅស្មើកម្រាលផ្ទះនោះទេ គឺមាននៅកន្លែងខ្ពស់ៗផ្សេងទៀត ។





ចូរព្យាយាមទុកដាក់គ្រឿងសង្ហារឹម និងវត្ថុទាំងឡាយនៅកន្លែងដដែល ទាំងនៅក្នុង និង ក្រៅផ្ទះរបស់អ្នក ។ សូមប្រាប់កូនឱ្យបានដឹង បើសិនជាអ្នករុះរើ ឬ យកអ្វីមួយទៅដាក់កន្លែងផ្សេង ។

### ➤ វិធីជួយកូនឱ្យចេះដឹងអ្វីដែលជាគ្រោះថ្នាក់

ចូរឱ្យដំណឹងដល់កូនអំពីអ្វីដែលអាចបង្កគ្រោះថ្នាក់ដូចជា ភ្លើង, ឆ្នាំងក្តៅ, និងកម្រាលឥដ្ឋសើម ។ ចូរដាក់អ្វីមួយរាំងជាសញ្ញាឱ្យដំណឹងដូចជា កម្រាល ឬ កន្ទេល ដើម្បីជួយឱ្យកុមារដឹងថាគេអាចមកជិតកន្លែងនោះបានត្រឹមណា ។







### ➤ វិធីជួយកូនឱ្យចេះបំលាស់ទីដោយសុវត្ថិភាព កាលណាបរិវេណទីធ្លាមិនរាបស្មើ

ចូរជួសជុលប្រហោង និងកន្លែងកំពឹកកំពកនៃកម្រាលក្តារក្រាលផ្ទះ ឬ កម្រាលឥដ្ឋឱ្យរាបស្មើតាមដែលអ្នកអាចធ្វើបាន ។




ចូរសង់បង្កាន់ដៃនៅក្បែរជណ្តើរទាំងនៅក្នុងនិងក្រៅផ្ទះរបស់អ្នក ។ ចូរធ្វើរនាំងកាត់ទទឹងជណ្តើរទាល់តែទារកអាចវារ ឬ ដើរចុះឡើងដោយសុវត្ថិភាព ។

ទាំងនេះគឺជាឧទាហរណ៍ខ្លះៗ ។ អ្នកនឹងស្វែងរកបញ្ហាសុវត្ថិភាព និងដំណោះស្រាយដោយខ្លួនឯងផ្ទាល់នៅក្នុងផ្ទះរបស់អ្នក ។ ចំពោះព័ត៌មានបន្ថែមអំពីការជួយកូនរបស់អ្នកឱ្យចេះបំលាស់ទីដោយសុវត្ថិភាព សូមអានជំពូកទី 10 ស្តីពី "ការបំលាស់ទីតាំង" នៅក្នុងផ្ទះ និង បរិវេណខាងក្រៅផ្ទះ ។






## ➤ វិធីធ្វើឱ្យទីធ្លាខាងក្រៅផ្ទះកាន់តែមានសុវត្ថិភាព

ចូរគ្រប ឬ លុបស្នាមភ្លោះ, ចង្ហូរទឹក, ថ្លុក, គ្រលុក, លូ និងរន្ធបើកចំហទាំងឡាយ ។ ចូរបង្ហាញកន្លែងទាំងនេះដល់កូន និងពន្យល់កូនពីអ្វីៗ និងហេតុអ្វីបានជាស្នាមភ្លោះ, ចង្ហូរទឹក, ថ្លុក, គ្រលុក និងលូទឹកនៅទីនោះ ។







ចូរធ្វើរបងដែលអាចប៉ះបានដោយសុវត្ថិភាព និងខ្ពស់ល្មមដែលមិនធ្វើឱ្យកុមារជំពប់លើវា ។ ចូរបង្ហាញក្មេងពីទីកន្លែងនៃរបង និងពន្យល់គេថារបងនេះសំរាប់ធ្វើអ្វី ។

ចូរដាក់របាំង ឬ ផ្លាកសញ្ញាជាដំណឹងនៅចន្លោះផ្ទះរបស់អ្នក និងផ្លូវដែលអ៊ូរអរមួយ ទាល់តែកូនរបស់អ្នកដឹងពីការនៅឱ្យឆ្ងាយពីចរាចរនៅលើផ្លូវនោះ ។ ចូរដាក់ផ្លាកសញ្ញាមួយ វាអាចជួយរំលឹកមនុស្សម្នាឱ្យបើកបរយឺតៗផងដែរ ។




បើសិនជាអ្នកស្គាល់ឪពុកម្តាយកុមារពិការភ្នែកឯទៀត អ្នកអាចធ្វើការរួមគ្នាស្តីពីសុវត្ថិភាព ។ ចូរព្យាយាមជួបប្រជុំជាមួយអ្នកជិតខាង ដើម្បីពិភាក្សាពីរបៀបដែលអាចធ្វើឱ្យសហគមន៍មានសុវត្ថិភាពកាន់តែច្រើនសំរាប់កុមារគ្រប់រូប (សូមអានជំពូកទី 15 សំរាប់ព័ត៌មានអំពីក្រុមឪពុកម្តាយ) ។

